សង្ខេបសំរាប់
គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ 2008 លេខ 01

# បដិដុល្លារូបនីយកម្ម⊙ នៅប្រទេសកម្ពុជា៖ ១០ឆ្នាំកន្លងទៅ

ដោយលោក ចាយ៉ាន់ មេណន់ *

"អស់ពេលជាយូរមកហើយ វិសាលភាពនៃ... ដុល្លារូបនីយកម្ម គ្មានទទួលរងឥទ្ធិពលអ្វីពីដំណើរការល្អប្រសើរឡើងនៃសេដ្ឋកិច្ចនោះទេ ។ ប៉ុន្តែបច្ចុប្បន្ន យើងឃើញមានប្រទេសជាច្រើនដែលធ្វើបដិដុល្លារូបនីយកម្មបានជោគជ័យ... ដូចជា អ៊ីស្រាអែល ប៉ូឡូញ ម៉ិចស៊ិក អេស៊ីប និងទួរគី ។ សញ្ញានៃការថយចុះកំរិតដុល្លារូបនីយកម្ម ក៏អាចពិនិត្យឃើញច្បាស់ដែរក្នុងបណ្តាប្រទេសអាមេរិកឡាទីន ដែលនៅទីនោះពីមុនមក ដុល្លារូបនីយកម្មហាក់ដូចជាមិនអាចផ្លាស់ប្តូរបានឡើយ។"

*Stanley Fischer* (2006)

ទេសាភិបាល នៃធនាគារប្រទេសអ៊ីស្រាអែល

## ១. សេចក្តីផ្តើម

កាលពី ១០ឆ្នាំមុន ខ្ញុំបានសរសេរអត្ថបទមួយសំរាប់ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (Menon 1998) ស្តីពីផលប្រយោជន៍ និងគុណវិបត្តិនៃដុល្លារូបនីយកម្មនៅកម្ពុជា ព្រមទាំងជំរើសគោលនយោបាយសំរាប់ពេលខាងមុខ ។ មានរឿងរ៉ាវច្រើនណាស់ បានកើតឡើងតាំងពីពេលនោះមក ។ កំណើនផសស ជាមធ្យមឡើងជិតដល់ ១០% ក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ដែលធ្វើឲ្យចំណូលក្នុងមនុស្សម្នាក់កើនឡើងជិតមួយជាពីរ (តារាង) ។ តួលេខប៉ាន់ស្មានភាពក្រីក្រ បានធ្លាក់ចុះប្រហែល ១% ក្នុងមួយឆ្នាំ ពី ៤៧% មកត្រឹម ៣៥% ក្នុងរយៈ ១០ឆ្នាំមកទល់ឆ្នាំ២០០៤ ប៉ុន្តែវិសមភាពបានកើនឡើង (World Bank 2007) ។ អតិផរណាលើថ្លៃទំនិញប្រើប្រាស់ បានធ្លាក់ចុះយ៉ាងខ្លាំងពី ៥៦% ជាមធ្យម (១៩៩០–៩៨) មកត្រឹម ៣,៥% (១៩៩៨–២០០៧) ។ អតិផរណាបានចាប់ផ្តើមកើនឡើងវិញនាពេលថ្មីៗនេះ ដោយស្ទុះឡើងយ៉ាងខ្លាំងក្នុងថ្លៃម្ហូបអាហារ និងថាមពល ប៉ុន្តែរឿងនេះក៏កើតមាននៅពាសពេញសាកលលោកដែរ ។[១] ការប្រមូលចំណូលរបស់រដ្ឋាភិបាលនាពេលថ្មីៗបានកើនឡើងលើសការរំពឹងទុក ហើយឱនភាពថវិកាបានថយចុះមកត្រឹមកំរិតអាចគ្រប់គ្រងបាន ។ ការរកឃើញប្រេង និងឧស្ម័ននាពេលថ្មីៗ អាចធ្វើឲ្យប្រទេសកម្ពុជាកាន់តែធូរធារ និងមានធនធានដ៏ចាំបាច់សំរាប់ដោះស្រាយបញ្ហាសេដ្ឋកិច្ច–សង្គមកិច្ចច្រើនបែបយ៉ាង បើសិនគេអាចគ្រប់គ្រងវាបានត្រឹមត្រូវ ។ សរុបមក ជោគជ័យខាងសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងមួយទសវត្សរ៍កន្លងមកនេះ អាចជាជោគជ័យដ៏ត្រចះត្រចង់បំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

ក្នុងបរិយាកាសដ៏ល្អនេះ គេពិនិត្យឃើញថា ប្រទេសកម្ពុជាសព្វថ្ងៃមានកំរិតដុល្លារូបនីយកម្មប៉ុនគ្នា រឺក៏ខ្ពស់ជាងកាលពី ១០ឆ្នាំមុនទៅទៀត ។ ដុល្លារនៅតែបំរើមុខងារទាំងបីនៃរូបិយវត្ថុ គឺការប្រើប្រាស់យ៉ាងទូលាយធ្វើជាមធ្យោបាយដោះដូរ ការរក្សាទុកទ្រព្យធន និងឯកតា

.............................................

១ គេព្រួយបារម្ភដែរអំពីចំនួនលើសនៃសាច់ប្រាក់ទំនេរ (excess liquidity) ដែលធ្វើឱ្យអតិផរណាកើនឡើង និងអសមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជាក្នុងការស្រូបយកសាច់ប្រាក់លើសនេះ ដោយសារកង្វះឧបករណ៍រូបិយវត្ថុដែលបណ្តាលមកពី ដុល្លារូបនីយកម្ម (សូមអានទៅវគ្គទី ២) ។

---

⊙ បដិដុល្លារូបនីយកម្ម = ការបំបាត់ចរាចររូបិយប័ណ្ណដុល្លារអាមេរិកនៅកម្ពុជា ។

* លោក ចាយ៉ាន់ មេណន់ (*Jayant Menon*) ធ្វើការនៅការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៃធនាគារអភិវឌ្ឍន៍អាស៊ី (*ADB*) និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន *CDRI* ។

ខ្ញុំសូមថ្លែងអំណរគុណដល់ Paul Dickie, Joao Farinha, Stephen Grenville, Sodeth Ly និង Anna Nakamura ដែលបានចូលរួមផ្តល់យោបល់កន្លងមកលើឯកសារជាសេចក្តីព្រាង ។ ទស្សនៈនៅក្នុងអត្ថបទនេះ ជារបស់អ្នកនិពន្ធផ្ទាល់ និងមិនមែនជារបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេ ។

គិត ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានប៉ាន់ស្មានថា ប្រាក់ដុល្លារមានចំណែកប្រហែល ៩០% ក្នុងចរាចររូបិយវត្ថុ គឺសឹងតែដូចគ្នានឹងស្ថានភាពកាលពីមួយទសវត្សរ៍មុន ។ ធនាគារជាតិនៃកម្ពុជាវាយតំលៃថា នៅឆ្នាំ២០០៦ ចំណែកប្រាក់បញ្ញើជារូបិយវត្ថុបរទេសក្នុងរូបិយវត្ថុទូទៅ (M2) បានកើនដល់កំរិតខ្ពស់បំផុតគឺ ៧៥% ដែលខ្ពស់ជាងឆ្ងាយណាស់ បើធៀបនឹងកំរិត ៥៤% នៅឆ្នាំ១៩៩៨ (តារាង) ។ បច្ចុប្បន្ននេះ ប្រាក់បញ្ញើនៅធនាគារ ប្រហែល ៩៧% គឺជាប្រាក់ដុល្លារ ។

ការមិនជឿនលឿនទៅមុខក្នុងការងារ បដិដុល្លារូបនីយកម្ម បានធ្វើឲ្យអ្នកវិភាគព័ត៌មានមួយចំនួនត្រូវខកចិត្ត ហើយអ្នកខ្លះបានជំរុញរដ្ឋាភិបាលឲ្យដើរតួនាទីកាន់តែផ្ចាល់ជាងមុន ពោលគឺចូលធ្វើអន្តរាគមន៍តែម្តង ។ម្យ៉ាងទៀតគេបារម្ភកាន់តែខ្លាំងថា ដំណើរការនេះប្រហែលជាពុំផ្លាស់ប្តូរទេ បើគ្មានការជំរុញបង្ខំ ។ នាឱកាសធ្វើវេទិកាសេដ្ឋកិច្ចកម្ពុជានៅថ្ងៃទី១៧ មករា ២០០៦ ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងនៅចុងបញ្ចប់សុន្ទរកថាបើកវេទិកាថា "ការគួបផ្សំអស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចដែលកំពុងរំខានដល់សេដ្ឋកិច្ចសាកលលោកសព្វថ្ងៃ តំរូវឲ្យកម្ពុជាប្រឹងប្រែងសកម្មជាងមុន ក្នុងការដាក់អនុវត្តគោលនយោបាយបដិដុល្លារូបនីយកម្ម..." ។ អត្ថបទមួយចុះផ្សាយនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ថ្ងៃទី១៥-២៨ មិថុនា ២០០៧ ក្រោមចំណងជើងថា "ការឈានទៅហាមឃាត់ប្រាក់ដុល្លារ" បានសង្ខេបពីអារម្មណ៍ជាទូទៅថា: "ការអំពាវនាវសាជាថ្មី ឲ្យបំបាត់ប្រាក់ដុល្លារពីការធ្វើចរាចរពាសពេញប្រទេសកម្ពុជានេះ មានការគាំទ្រពីគណបក្សនយោបាយទាំងពីរ ហើយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយចំនួនបានប្រកាសថា ការហាមឃាត់ គឺជាបញ្ហាអធិបតេយ្យភាព និងមោទនភាពជាតិ ។ វិធានការធ្វើបដិដុល្លារូបនីយកម្មសេដ្ឋកិច្ចកម្ពុជាឲ្យស្រេចបាច់ គេបានដាក់វាទៅម្ខាងជាច្រើនឆ្នាំមកហើយ..." ។ អត្ថបទដដែល បានដកស្រង់ប្រសាសន៍លោកជំទាវ ជូឡុង សូមូរ៉ា ជាសមាជិកសភាមកពីគណបក្ស សម រង្ស៊ីថា: "បដិដុល្លារូបនីយកម្មកាន់តែសំខាន់ណាស់ទៀតនៅពេលនេះ... ត្រូវតែធ្វើក្រឹត្យច្បាប់ ត្រូវតែហាមឃាត់! រឿងបែបនេះគេទទួលយកមិនបានទេនៅកន្លែងផ្សេងទៀត" ។[២] ការខកចិត្តនេះគេអាចយល់បាន ប៉ុន្តែតើការដាក់អនុវត្តបដិដុល្លារូបនីយកម្មពិតជាជំរើសគោលនយោបាយដ៏ត្រឹមត្រូវមែនឬយ៉ាងណា?

លោក Menon (១៩៩៨) បានវែកញែកថា: "...ដុល្លារូបនីយកម្មមិនមែនជាបញ្ហាទេ វាគ្រាន់តែជារោគសញ្ញាប៉ុណ្ណោះ ។ បញ្ហាចោទ (ឬមូលហេតុ) គឺកង្វះទំនុកចិត្តលើប្រាក់រៀល ឬឯរោគសញ្ញា (ឬផលប៉ះពាល់) គឺជាការប្រើរូបិយវត្ថុមួយផ្សេងទៀត ដូចជា ដុល្លារអាមេរិកជាដើម ។ បញ្ហានេះផុសចេញពីប្រព័ន្ធរូបិយវត្ថុនៅអន់ខ្សោយ ភាពមិនប្រាកដប្រជាខាងនយោបាយនិងសេដ្ឋកិច្ច និងរចនាសម្ព័ន្ធខាងស្ថាប័ននិងច្បាប់នៅទន់ខ្សោយ ។ ចំណុចទាំងនេះ សុទ្ធតែជាបញ្ហាត្រូវដោះស្រាយដោយផ្ចាល់ ។ នៅពេលដោះស្រាយវាបានហើយ រោគសញ្ញាពោលគឺ ដុល្លារូបនីយកម្ម នឹងលែងជាឧបសគ្គទៀតហើយ" ។

ភាពមិនប្រាកដប្រជាខាងនយោបាយ និងសេដ្ឋកិច្ចបានថយចុះច្រើន រចនាសម្ព័ន្ធច្បាប់និងស្ថាប័ន ក៏បានប្រសើរឡើង ហើយប្រព័ន្ធរូបិយវត្ថុទៀតសោត ក៏អាចចាត់ទុកថា បានរីកចំរើនពេញបន្ទុកដែរ ។ ដូច្នេះហេតុអ្វីបានជាប្រទេសកម្ពុជា នៅតែមានដុល្លារូបនីយកម្មយ៉ាងខ្លាំងដូចសព្វថ្ងៃ?

ក្នុងអត្ថបទនេះ យើងពិនិត្យមើលបញ្ហាឡើងវិញ និងព្យាយាមបកស្រាយថា ហេតុអ្វីបានជាសេដ្ឋកិច្ចនយោបាយ និងការវិវត្តប្រសើរឡើងផ្សេងៗទៀត មិនអាចញ៉ាំងឲ្យបដិដុល្លារូបនីយកម្មចាប់ផ្តើមបាន ។ យើងបានវែកញែកថា ភាពមិនគួរទៅរួចមួយដែលកម្ពុជាមានសេដ្ឋកិច្ចនិងនយោបាយប្រែប្រួលប្រសើរឡើង និងមានដុល្លារូបនីយកម្ម អូសបន្លាយរហូតដល់មួយទសវត្សរ៍បែបនេះ គឺពិតជាអាចបកស្រាយបាន ហើយដំណោះស្រាយខាងគោលនយោបាយ ដែលគេបានស្នើឡើងកាលពីមួយទសវត្សរ៍មុន ក៏នៅតែត្រឹមត្រូវដដែលសំរាប់ពេលនេះ ដោយគ្រាន់តែត្រូវកែសំរួលបន្តិចបន្តួចប៉ុណ្ណោះ ។

ឯកសារនេះចែកចេញជា ៥ផ្នែក ។ ផ្នែកទី២ ពិនិត្យពីមូលហេតុដែលនាំឱ្យដុល្លារូបនីយកម្មកើនឡើងនាពេលថ្មីៗ ដោយញែកចេញពីគ្នារវាងដុល្លារូបនីយកម្មជា "ដំណឹងល្អ" និងដុល្លារូបនីយកម្ម "ដំណឹងអាក្រក់" ។ យើងវែកញែកថា រឿងនេះជាចំណែកមួយនៃអន្តរកាល ដូច្នេះវាមានលក្ខណៈបណ្តោះអាសន្ន ហើយចំណុចដែលត្រូវបកស្រាយ គឺកត្តារយៈពេលវែងដែលនាំឲ្យ ដុល្លារូបនីយកម្មនៅឋិតថេរបានក្នុងប្រទេសកម្ពុជា ។ ផ្នែកទី៣ ព្យាយាមពន្យល់ថា ភាពឋិតថេរនេះ បណ្តាលមកពីរបៀបវារៈកំណែទំរង់ដែលមិនទាន់ចប់សព្វគ្រប់ និងភាពស្ពឹកស្រពន់ និងអាប់អួរនៅក្នុងប្រព័ន្ធ ។ កាលៈទេសៈពិសេសនៅពេលដុល្លារហូរចូលមកក្នុងសេដ្ឋកិច្ចកម្ពុជា គួបផ្សំនឹងកំរិតយ៉ាងខ្ពស់នៃដុល្លារូបនីយកម្ម ផ្តល់គំនិតថា ដំណើរការដុល្លារូបនីយកម្មទំនងជាអូសបន្លាយយូរជាងករណីធម្មតា ។ ផ្អែកលើការបកស្រាយទាំងនេះផ្នែកទី៤ ត្រិះរិះពិចារណាលើជំរើសគោលនយោបាយគ្រប់បែបយ៉ាង ចាប់តាំងពីការព្យាយាមពង្រឹងអនុវត្តន៍បដិដុល្លារូបនីយកម្ម រហូតដល់ការធ្វើដុល្លារូបនីយកម្មជាផ្លូវការ ។ ក្នុងចន្លោះជំរើសគោលនយោបាយទាំងពីរនេះ យើងក៏មានជំរើសដូចជា ក្រុមប្រឹក្សារូបិយវត្ថុ សហភាពរូបិយវត្ថុ

........................................

២ ដូចក្នុងចំណងជើងឯកសារនេះដែរ វាជារឿងមិនគួរឱ្យជឿដែលឯកឧត្តម ជាម យៀប ប្រធានគណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភាជាតិ បន្តអះអាងថា គិតមកទល់ពេលនេះ ឯកឧត្តមបានជំរុញឱ្យពង្រឹងអនុវត្តបដិដុល្លារូបនីយកម្មជាបន្តបន្ទាប់អស់ពេលមួយទសវត្សរ៍មកហើយ: "ខ្ញុំបានលើកគំនិតហាមឃាត់ប្រាក់ដុល្លារតាំងពី ៩ឆ្នាំមុន (និយាយនៅឆ្នាំ២០០៧) ។ ខ្ញុំបាននិយាយជាមួយឯកឧត្តមគាតឈន់ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាជាច្រើនលើកអំពីវិធីធ្វើបដិដុល្លារូបនីយកម្ម" (Phnom Penh Post, 15-28 June 2007) ។

និង "វិធីសាស្ត្រលូកដៃអន្តរាគមន៍ដោយពន្លឿនកំណែទំរង់" ។ វគ្គទី៥ សន្និដ្ឋាន ។

## ២. ការបកស្រាយពីកំណើនដុល្លារូបនីយកម្មនាពេលថ្មីៗ: "ដំណើរល្អ" និង "ដំណើរអាក្រក់" នៃដុល្លារូបនីយកម្ម

កំណើនកំរិតដុល្លារូបនីយកម្ម ជាធម្មតា ច្រើនកើតមានក្នុងអំឡុងពេលមានអស្ថិរភាពនយោបាយ រឺម៉ាក្រូសេដ្ឋកិច្ច ។ ដូច្នេះហេតុអ្វីបានជាដុល្លារូបនីយកម្មនៅកម្ពុជាកើនឡើងនាពេលថ្មីៗ ក្នុងអំឡុងពេលដែលកម្ពុជាទទួលបានជោគជ័យដ៏ត្រចះត្រចង់ខាងសេដ្ឋកិច្ចបែបនេះ? កំរិតដុល្លារូបនីយកម្ម បច្ចុប្បន្នអាចបណ្តាលមួយចំណែកមកពីដំណើរការសេដ្ឋកិច្ចល្អវិសេស មិនមែនដំណើរការធ្លាក់ចុះសេដ្ឋកិច្ចនោះទេ ។

កំណើនទំនុកចិត្តលើស្ថានភាពសេដ្ឋកិច្ច/នយោបាយ ក៏រួមចំណែកខ្លះដែរ ដល់កំណើនចំណែកប្រាក់បញ្ញើជារូបិយវត្ថុបរទេសនៅក្នុងរូបិយវត្ថុទូទៅ M2 ហើយក្នុងនេះ មានទឹកប្រាក់ដ៏ច្រើនៗរបស់វិនិយោគិនទាំងបរទេស និងក្នុងស្រុកដែលហូរចូលមក ។ រឿងសំងាត់មួយដែលគេដឹងឮគ្រប់គ្នា គឺទឹកប្រាក់ជារូបិយវត្ថុបរទេសយ៉ាងច្រើនៗដែលនិវាសជន និងអនិវាសជនកម្ពុជា ផ្ញើទុកក្នុងធនាគារនៅក្រៅប្រទេស (ដូចជាធនាគារនៅសិង្ហបុរី ហុងកុង...) បានហូរចូលមកកម្ពុជាវិញនាពេលថ្មីៗ ។ លំហូរនេះមួយចំនួនបានយកទៅវិនិយោគពិតប្រាកដមែន ប៉ុន្តែតាមមើលទៅ ភាគច្រើនគឺទុនឆក់ឱកាសកេងចំណេញដែលជាការឆ្លើយតប និងជាកត្តាជំរុញបន្ថែមនូវអតិផរណាថ្លៃដី ។ របាយការណ៍វិនិយោគសាកលលោកចុងក្រោយរបស់ UNCTAD បានប៉ាន់ស្មានថា ស្តុកនៃវិនិយោគផ្ទាល់ពីបរទេស (FDI) បានកើនពី ៣៨លានដុល្លារនៅឆ្នាំ ១៩៩០ ដល់ ១,៦ពាន់លានដុល្លារនៅឆ្នាំ២០០០ និង ៣,៥ពាន់លានដុល្លារនៅឆ្នាំ២០០៧ ។ នៅឆ្នាំ២០០៧ លំហូរចូលប្រចាំឆ្នាំមាន ៨២០លានដុល្លារ រឺធំជាង ៥ដង នៃលំហូរចូលប្រចាំឆ្នាំជាមធ្យមក្នុងអំឡុងឆ្នាំ១៩៩០–២០០០ (តារាង) ។ កំណើនដុល្លារូបនីយកម្មតាមរូបភាពនេះ បង្ហាញពីកំណើនទំនុកចិត្តលើសេដ្ឋកិច្ច មិនមែនការធ្លាក់ចុះទំនុកចិត្តនោះទេ ។[៣]

កត្តាជាដំណើរល្អផ្សេងទៀត ដែលជំរុញកំណើនដុល្លារូបនីយកម្ម គឺនៅឆ្នាំ២០០៤ ប្រទេសកម្ពុជាបានចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក (WTO) ហើយសព្វថ្ងៃបានបើកចំហ និងមាននិន្នាការទាក់ទងទៅខាងក្រៅ ច្រើនជាងកាលពី ១០ឆ្នាំមុនច្ងាយណាស់ ។ ពាណិជ្ជកម្មបានរីកដុះដាល ហើយចំណែកការនាំចេញនៅក្នុងផលិតផលក្នុងស្រុកសរុប (ផសស) កើនពី ៣០% នៅឆ្នាំ១៩៩៨ ដល់ ៧០% សព្វថ្ងៃនេះ ។ សន្ទស្សន៍ការបើកទូលាយខាងពាណិជ្ជកម្ម មានកំរិត ១២០% នាបច្ចុប្បន្ន ។ ក្នុងសេដ្ឋកិច្ចអន្តរកាលភាគច្រើន ចលនាដោះដូរ និងមូលធនស្ទើរតែទាំងអស់ តែងប្រើប្រាស់រូបិយវត្ថុបរទេសដែលជាទូទៅគឺប្រាក់ដុល្លារ ។ ខាងហិរញ្ញវត្ថុទៀតសោត គេឃើញមានកំណើនរូបិយវត្ថុនីយកម្មយ៉ាងលឿន (ពីកំរិតដើមមួយដ៏ទាប) និងកំណើនអន្តរការីកម្មហិរញ្ញវត្ថុ (ពីកំរិតដើមដ៏ទាបដែរ) ប៉ុន្តែកំនើនទាំងពីរនេះបានរួមចំនែកបង្កើនដុល្លារូបនីយកម្ម ។ គេសឹងតែច្បាស់ណាស់ដែរដែលដុល្លារូបនីយកម្ម វាជួយសំរួលដល់ការរីកលូតលាស់ខាងហិរញ្ញវត្ថុ ។

កំណើនចំណែកប្រាក់ដុល្លារដោយសារកត្តាទាំងនេះ គ្មានអ្វីគួរឱ្យបារម្ភឡើយ ។ កត្តាទាំងនេះមានផលប៉ះពាល់សំខាន់ ខាងបរិមាណ មិនមែនខាងជំនួសគ្នានោះទេ គឺថា ខណៈដែលបរិមាណប្រាក់រៀលសឹងតែនៅថេរ លំហូរចូលប្រាក់ដុល្លារយ៉ាងច្រើនៗ នាំឲ្យចំណែកប្រាក់ដុល្លារកើនឡើងក្នុងចំនួនសរុប ។ ប្រជាជនមិនមែនកំពុងយកដុល្លារមកជំនួសប្រាក់រៀលនោះទេ ប៉ុន្តែប្រតិបត្តិការប្រភេទទាំងនេះ ជាធម្មតាផ្អែកលើដុល្លារ ។ ការបន្តចាត់ទុកដុល្លារជា រូបិយវត្ថុដែលប្រើប្រាស់ជាក់ស្តែងនៅប្រទេសកម្ពុជា បានពង្រឹងស្ថានភាពនេះថែមទៀត ។

កត្តាជា "ដំណើរល្អ" ដែលបណ្តាលឱ្យកើនដុល្លារូបនីយកម្ម គឺជាចំណែកមួយនៃដំណាក់កាលអន្តរកាល ។ ក្នុងបដិដុល្លារូបនីយកម្ម ត្រូវយកប្រាក់រៀលទៅជំនួសដុល្លារ តែរឿងនេះមិនទាន់ចាប់ផ្តើមនៅឡើយទេ ។ បន្ទាប់មក គួរងាកទៅពិនិត្យកត្តារយៈពេលវែងដែលជួយទ្រទ្រង់ដុល្លារូបនីយកម្មឲ្យនៅឋិតថេរ ។

## ៣. ការបកស្រាយពីការឋិតថេរនៃដុល្លារូបនីយកម្ម: កំរិតកំណែទំរង់ដ៏ចាំបាច់ និង "ប្រវត្តិ"

នៅមានកត្តាពាក់ព័ន្ធគ្នាពីរដែលពន្យល់ពីការឋិតថេរនៃដុល្លារូបនីយកម្មនៅកម្ពុជាគឺ ទី១ កំរិតវិទំហំនៃកំណែទំរង់ផ្ទាល់ និងទី២ ប្រវត្តិ (hysteresis) រឺការពិតជាក់ស្តែងដែលប្រវត្តិជាកត្តាសំខាន់ ។

សំរាប់កំណែទំរង់ ចំណុចសំខាន់មិនមែន តើកម្ពុជាជឿនលឿនទៅមុខបានប៉ុណ្ណាក្នុងទសវត្សរ៍កន្លងទៅនោះទេ ក៏ប៉ុន្តែតើកម្ពុជាត្រូវសំរេចឲ្យបានប៉ុណ្ណាទៀត ។ ពិតហើយកម្ពុជាសំរេចបានលទ្ធផលច្រើនណាស់ដែលប្រហែលជាច្រើនជាងការរំពឹងទុកទៅទៀត ប៉ុន្តែនៅមានការងារច្រើនទៀតដែលត្រូវធ្វើ ទើបអាចបំបាត់ចោលភាពមិនប្រាកដប្រជាបានច្រើនគួរសម ។ កន្លងមកកំណើនមានសន្ទុះខ្លាំង គួរឲ្យកោតសរសើរ ហើយអស្ថិរភាពនយោបាយ ក៏បានថយចុះច្រើនដែរ ប៉ុន្តែកម្ពុជានៅតែជាប្រទេសមានប្រាក់ចំណូលទាប មានវិសមភាពនិងភាពក្រីក្រយ៉ាងច្រើន និងនៅមានអស្ថិរភាពនយោបាយខ្លះទៀតផង ។

.............................................

៣ ក្នុងនេះទិដ្ឋភាពមួយដែលទាក់ទិននឹងដុល្លារូបនីយកម្ម គឺជាអសមត្ថភាពរបស់ធនាគារជាតិក្នុងការស្រូបយកចំនួនលើសនៃសាច់ប្រាក់ទំនេរ ពីព្រោះពុំមានឧបករណ៍រូបិយវត្ថុគ្រប់គ្រាន់ ។ គេទទួលស្គាល់កាន់តែច្រើនថា សាច់ប្រាក់ទំនេរលើសនេះ បូករួមនឹងថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ កំពុងបង្កើនអតិផរណានាបច្ចុប្បន្ន ។ ការកែប្រែកំរិតធនបំរុងអាចជួយបានខ្លះដែរ ប៉ុន្តែក្នុងបរិបទសព្វថ្ងៃ វាជាឧបករណ៍មិនសូវសក្តិសិទ្ធិទេ ពីព្រោះដុល្លារូបនីយកម្មបានធ្វើឱ្យលំហូរមូលធនក្លាយជាផ្នែកមួយនៃស្តុករូបិយវត្ថុតែម្តង ដោយគ្មានច្នងកាត់ប្រព័ន្ធហិរញ្ញវត្ថុទេ ។

## ឯកសារយោង

de Zamarocksy, Mario & Sophana Sa (2002), *Macroeconomic Adjustment in a Highly Dollarised Economy: The Case of Cambodia*, Working Paper 02/92 (Washington, DC: International Monetary Fund)

Fischer, Stanley (2006), “Dollarisation”, Keynote address at the 75th Anniversary Conference of the Central Bank of the Republic of Turkey, Istanbul, 13–15 December 2006, on “Dollarisation: Consequences and Policy Options”. Downloadable from: <http://www.bankisrael.gov.il/deptdata/neumim/neum215e.pdf>.

Kang, K (2005), “Is Dollarisation Good for Cambodia?” *Global Economic Review*, 34(2), pp. 201–212

Menon, Jayant (1998), “De-dollarising Cambodia” *Cambodian Development Review*, 2(2), pp. 6–9

Menon, Jayant (2007), “Would You Like to Pay in Dollars, Baht or Kip? Economic Consequences of Multiple Currencies in Lao PDR” *Journal of GMS Development Studies*, 3(2), pp. 35–47. Downloadable from: http://www.adbi.org/files/dp58.dollarisation.multiple.currency.2.pdf.

Menon, Jayant (2008), “Dealing with Dollarisation: What Options for the Transitional Economies of Southeast Asia?” *Journal of the Asia-Pacific Economy* 13(2), pp. 131–146. Downloadable from: http://www.adbi.org/files/dp63.dollarisation.transitional.economies.southeastasia.pdf.

Unteroberdoerster, Olaf (2004), *Banking Reform in the Lower Mekong Countries*, IMF Policy Discussion Paper PDP/04/5 (Washington, DC: IMF)

World Bank (2007), *Sharing Growth: Equity and Development in Cambodia* (Washington, DC: World Bank)

### តារាង: សូចនាកររូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចជ្រើសរើសពីឆ្នាំ១៩៩៨-២០០៧

| | 98-07 មធ្យមភាគ | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|
| កំណើន ផសស (%) | 9.3 | 5.0 | 12.6 | 8.4 | 7.7 | 6.9 | 8.5 | 10.0 | 13.5 | 10.8 | 9.6 a/ |
| កំណើនចំណូលក្នុងមនុស្សម្នាក់ (%) | 5.5 | -2.4 | 4.2 | 5.0 | 3.3 | 3.6 | 6.7 | 8.2 | 11.2 | 8.2 | 7.2 |
| អត្រាអតិផរណា (%/ឆ្នាំ) | 3.8 | 12.6 | 0.0 | 0.5 | 0.3 | 3.3 | 1.2 | 3.8 | 5.9 | 4.7 | 5.9 |
| ឱនភាពថវិកា (%នៃ ផសស) | 4.9 | 5.5 | 3.9 | 5.3 | 6.6 | 6.4 | 6.7 | 4.6 | 3.4 | 3.0 | 3.2 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ) | 252 | 121 | 144 | 112 | 142 | 139 | 74 | 121 | 375 | 475 | 820 |
| ប្រាក់បញ្ញើជារូបិយវត្ថុបរទេស M2 (%) | 67.5 | 54.0 | 60.0 | 68.0 | 70.0 | 69.0 | 69.0 | 71.1 | 71.4 | 75 b/ | NA |

កំណត់សំគាល់:

a/ ការប៉ាន់ស្មានរបស់ *ADB* ក្នុងឯកសារ *Asian Development Outlook* 2008 ។

b/ ទិន្នន័យបានពីធនាគារជាតិនៃកម្ពុជា

ប្រភព:

ឯកសារ *Asian Development Outlook*, various issues.

IMF Country Reports, various issues.

ធនាគារជាតិនៃកម្ពុជា

**CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☏ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨

(៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh

website: http://www.cdri.org.kh

នៅពេលនេះ កំហិតដ៏ធំវាជាប់ពាក់ព័ន្ធនឹងកំរិតអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ធនាគារ និងប្រព័ន្ធរូបិយវត្ថុ ក៏ដូចជា អវត្តមានជាបន្តនូវទ្រព្យសកម្មដែលមានការប្រាក់ជារៀល ។ កម្ពុជាបន្តតស៊ូពុះពារនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍប្រព័ន្ធធនាគារមួយដែលអាចរស់រានបានដោយសង្កត់ធ្ងន់លើក្របខ័ណ្ឌច្បាប់ និងការត្រួតពិនិត្យដ៏រឹងមាំ ។ ខុសប្លែកពីសេដ្ឋកិច្ចអន្តរកាលឯទៀត។ កម្ពុជាប្រឈមមុខនឹងបញ្ហាកសាងប្រព័ន្ធធនាគារឡើងវិញ មិនមែនការកែប្រែប្រព័ន្ធធនាគារទេ ។ ថ្វីត្បិតការរៀបចំរចនាសម្ព័ន្ធវិស័យធនាគារឡើងវិញ បានជឿនលឿនទៅមុខសន្ធឹកណាស់ហើយក្តី ប៉ុន្តែធនាគារពាណិជ្ជកម្មក្រៅប្រទេសដែលរដ្ឋកាន់កាប់នៅតែរក្សាតួនាទីខ្លួនជាតួអង្គសំខាន់ដដែល ។ ម្យ៉ាងទៀត ការតំរូវឱ្យមានអាជ្ញាប័ណ្ណដោយធូររលុង បានធ្វើធនាគារប្រភេទចំរុះទុន (joint-venture banks) កើនចំនួនច្រើនណាស់ ដែលដាក់សម្ពាធទៅលើសមត្ថភាពបង្កើតច្បាប់គ្រប់គ្រង និងសមត្ថភាពត្រួតពិនិត្យរបស់កម្ពុជា ហើយបញ្ហាផ្សេងៗ ដែលចោទឡើងបានរារាំងដល់ការសាងកសាងទំនុកចិត្តលើប្រព័ន្ធធនាគារ (Unteroberdoerster 2004) ។ ជាលទ្ធផលទោះបីកំរិតរូបិយវត្ថុនីយកម្មបានកើនឡើងក្តីប៉ុន្តែជាទូទៅកម្ពុជានៅតែជាប្រទេសមិនប្រើធនាគារដដែល ។

ស្ថាប័ន និងច្បាប់ជាច្រើន បានកើតឡើងនៅទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែត្រូវបង្កើតជាច្រើនបន្ថែមទៀត ហើយក៏ត្រូវដោះស្រាយបញ្ហាសំខាន់ៗមួយចំនួន ដែលទាក់ទងនឹងការពង្រឹងអនុវត្តច្បាប់ទាំងនេះផង ។

សរុបមកទោះកម្ពុជាសំរេចបានលទ្ធផលខាងសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយយ៉ាងត្រចះត្រចង់ក្នុងទសវត្សរ៍ចុងក្រោយនេះក្តី ក៏នៅតែមិនទាន់គ្រប់គ្រាន់ ដើម្បីចាប់ផ្តើមធ្វើបដិដុល្លារូបនីយកម្ម ។ កំណែទំរង់ខាងរូបិយវត្ថុ និងហិរញ្ញវត្ថុ មានសន្ទុះយឺត ប៉ុន្តែគឺកំណែទំរង់ទាំងនេះហើយដែលមានប្រសិទ្ធភាពជាងគេ ដើម្បីទាញដុល្លារូបនីយកម្មឲ្យវិលថយក្រោយវិញ ។

បញ្ហាទាំងឡាយដូចខាងលើបាននាំទៅដល់កត្តាទី២ គឺប្រវត្តិ ។ ទស្សនៈនៃប្រវត្តិនេះ មានតាំងពីភាពស្ពឹកស្រពន់ធម្មតា ការពឹងផ្អែកលើផ្លូវធ្លាប់ប្រើ និងរហូតដល់ភាពរឹងកំព្រឹសមិនអាចផ្លាស់ប្តូរបាន ។ ជាក់ស្តែង ទស្សនៈនេះលើកជាសំខាន់ថា ក្នុងបញ្ហាប្រវត្តិនេះ អាចមានរឿងបត់បែន រឺអាប់អួរ (non-linearities or “stickiness”) នៅក្នុងប្រព័ន្ធដែលគួរយកមកពិចារណា ដើម្បីស្វែងយល់ពីដំណើរការរឺដោះស្រាយវា ។ កាលៈទេសៈដែលកើតមានដុល្លារូបនីយកម្មនៅកម្ពុជា វាខុសពីកាលៈទេសៈនៅក្នុងប្រទេសផ្សេងទៀត ហើយចំណុចនេះ ក៏សំខាន់ដែរ ដើម្បីស្វែងយល់ពីភាពឋិតថេរនៃដុល្លារូបនីយកម្ម ។

ដុល្លារូបនីយកម្មនៅកម្ពុជា ជាកេរ្តិ៍ដំណែលផ្ទាល់នៃការបំផ្លិចបំផ្លាញស្ថាប័នសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងទសវត្សរ៍១៩៧០ ការគ្រប់គ្រងសេដ្ឋកិច្ចមិនត្រឹមត្រូវក្នុងទសវត្សរ៍១៩៨០ និងលំហូរចូលប្រាក់ដុល្លារយ៉ាងច្រើនក្នុងសម័យ UNTAC នៅដើមទសវត្សរ៍១៩៩០ ។ ដូចនេះ ខុសប្លែកពីប្រទេសឯទៀតដែលអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអតិផរណាលោតផ្លោះមួយរយៈ វាបង្កឬបង្កើនដុល្លារូបនីយកម្ម នៅប្រទេសកម្ពុជាគឺ ព្រឹត្តិការណ៍ខាងរដ្ឋបាល និងនយោបាយទៅវិញទេដែលជាប្រភពសំខាន់បំផុតនៃដុល្លារូបនីយកម្ម ។

នៅកម្ពុជា អន្តរាគមន៍ UNTAC បានប្រើអស់ថវិកាយ៉ាងច្រើនដល់ ១,៧ពាន់លានដុល្លារ ដែលធ្វើឱ្យមានដុល្លារូបនីយកម្មកំរិតខ្ពស់ជាខ្លាំង ។ ជំនួយបរទេស និងការផ្ទេរប្រាក់ឯកជនច្រើនៗចូលមកកម្ពុជាក៏សុទ្ធតែប្រាក់ដុល្លារដែរ ហើយភាពមិនប្រាកដប្រជាខាងនយោបាយ និងសេដ្ឋកិច្ចនៅទសវត្សរ៍១៩៩០ បានរក្សាដុល្លារូបនីយកម្មកំរិតខ្ពស់នេះបន្តទៀត ។ កម្ពុជាជាប្រទេសមានកំរិតដុល្លារូបនីយកម្ម ខ្ពស់ជាងគេនៅអាស៊ី និងស្ថិតក្នុងចំណោមប្រទេសមានកំរិតដុល្លារូបនីយកម្មខ្ពស់ៗបំផុតក្នុងសាកលលោក ។ ទំហំ និងរយៈពេលនៃដុល្លារូបនីយកម្មបានគួបផ្សំគ្នាបង្កើតភាពស្ពឹកស្រពន់ និងការពឹងផ្អែកលើផ្លូវធ្លាប់ប្រើយ៉ាងខ្លាំងក្នុងប្រព័ន្ធ ។ ដូច្នេះត្រូវមានទឹកប្រាក់ និងរយៈពេលច្រើនប៉ុនគ្នា រឺច្រើនជាងនេះទៀត ទើបអាចធ្វើឲ្យដុល្លារូបនីយកម្មវិលបញ្ច្រាសវិញបាន ។ កម្ពុជារងឥទ្ធិពលខាងប្រវត្តិសាស្ត្រខ្លាំងជាងវៀតណាម និងឡាវ ដូច្នេះបដិដុល្លារូបនីយកម្មនៅកម្ពុជា ក៏ត្រូវប្រើពេលយូរជាងដែរ ។

លោក Fischer (2006) បានលើកថា “ដុល្លារូបនីយកម្ម វាមានអាយុវែង ដោយជាទូទៅវាអាចរស់រានបានយ៉ាងយូរក្រោយពេលចប់អស្ថិរភាពដែលបង្កវាឡើងនោះទៀត” ។ កាលៈទេសៈពិសេសនៃការហូរចូលប្រាក់ដុល្លារមកកម្ពុជា គួបផ្សំនឹងដុល្លារូបនីយកម្មកំរិតខ្ពស់ពីដំបូង អាចធ្វើឲ្យដុល្លារូបនីយកម្មនៅកម្ពុជា នៅឋិតថេរបានយូរណាស់ ។ លើសពីនេះ ដូចបានបង្ហាញពីខាងដើម ដំណើងល្អខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាពេលថ្មីៗ បានជួយបង្កើនដុល្លារូបនីយកម្ម ដូច្នេះបដិដុល្លារូបនីយកម្ម ទំនងត្រូវចំណាយពេលកាន់តែយូរថែមទៀត ។ ប្រសិនបើហេតុផលទាំងនេះត្រឹមត្រូវទាំងអស់ គេត្រូវតែអត់ធ្មត់ ពីព្រោះដុល្លារូបនីយកម្មកំរិតខ្ពស់ដែលអូសបន្លាយយូរមកហើយ វាអាចបង្កើតបានប្រវត្តិច្រើន ។ ប្រតិកម្មដោយការខកចិត្ត តាមរយៈការព្យាយាមពង្រឹងអនុវត្តន៍បដិដុល្លារូបនីយកម្ម ទំនងជាមិនបានជោគជ័យទេ និងអាចធ្វើឲ្យខូចការទៀតផង ហើយជាលទ្ធផល គេនឹងត្រូវរង់ចាំកាន់តែយូរ ដើម្បីអោយដុល្លារូបនីយកម្មវិលបញ្ច្រាសមកវិញ ។

ដូចបានបញ្ជាក់ដោយលោក Fiscer នៅខាងលើ មានភស្តុតាងនៅអន្តរជាតិជាច្រើនដែលគាំទ្រឱ្យរក្សាការអត់ធ្មត់ ។ កម្ពុជាសព្វថ្ងៃក៏ស្ថិតក្នុងចំណោមប្រទេសដែលដុល្លារូបនីយកម្មហាក់ដូចមិនអាចផ្លាស់ប្តូរកើតដែរ ។ ប៉ុន្តែមានឧទាហរណ៍ជាច្រើននៃបដិដុល្លារូបនីយកម្មដែលបានជោគជ័យ ព្រោះមានការអត់ធ្មត់ គួបផ្សំនឹងការតាំងចិត្តអនុវត្តកំណែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុដ៏សមរម្យអាចជឿទុកចិត្តបាន ។ គេក៏មានឧទាហរណ៍ច្រើនដែរនៃការព្យាយាមពង្រឹងអនុវត្តន៍បដិដុល្លារូបនីយកម្មដែលទទួលបរាជ័យធ្ងន់ធ្ងរ ។

ទីភ្នាក់ងារមីក្រូហិរញ្ញវត្ថុ ដែលបានត្អូញត្អែរជាញឹកញាប់ពីកង្វះប្រាក់រៀលសំរាប់ដោះស្រាយតំរូវការផ្តល់កំចីទៅឲ្យអ្នកខ្ចីប្រាក់តូចតាច ។ គេប៉ាន់ស្មានថា គ្រាន់តែផ្នែកមីក្រូហិរញ្ញវត្ថុមួយមុខ ត្រូវការដល់ទៅ ១២០ពាន់លានរៀលនៅឆ្នាំ២០០៨ ហើយតួលេខនេះវាធំជាងសាច់ប្រាក់ដែលមាននៅក្នុងទីផ្សារ។[៧] តាមស្មានការរឹតបន្តឹងការផ្គត់ផ្គង់ប្រាក់រៀល គឺដើម្បីជៀសវាងការធ្លាក់ថ្លៃប្រាក់រៀលថែមទៀត ទល់នឹងដុល្លារ ។ ប្រសិនបើមានតំរូវការប្រាក់រៀលកាន់តែច្រើនសំរាប់ផ្តល់កំចីមែននោះ ការបារម្ភខាងលើហាក់ដូចជាមិនសមហេតុផលឡើយ ។

................................................

៧ ចំណុចនេះមានចុះក្នុងអត្ថបទ "មីក្រូហិរញ្ញវត្ថុត្រូវការប្រាក់រៀលច្រើនថែមទៀតសំរាប់ផ្តល់កំចី" Phnom Penh Post, ថ្ងៃទី១៧ ធ្នូ ២០០៧ ។

សរុបមក ច្បាប់/បទប្បញ្ញត្តិដែលមានចែងដោយចំហ រឺដោយបង្កប់ ជួយសំរួលដល់ការប្រើដុល្លារ វាធ្វើឱ្យខូចប្រយោជន៍ ដូចគ្នានឹងច្បាប់/បទប្បញ្ញត្តិដែលតំរូវឱ្យប្រើប្រាក់រៀល ដើម្បីធ្វើបដិដុល្លារូបនីយកម្មក្នុងរយៈពេលវែងដូច្នោះដែរ ។ ច្បាប់ និងបទប្បញ្ញត្តិទាំងនេះ គេអាច និងគួរតែបំបាត់ចោលភ្លាមៗ ។ ការរក្សាបាន និងកសាងបន្តទៀតលើជោគជ័យខាងម៉ាក្រូសេដ្ឋកិច្ចនិងនយោបាយក្នុងទសវត្សរ៍កន្លងទៅនេះ គួបផ្សំនឹងការអនុវត្តបានចប់សព្វគ្រប់ និងឆាប់រហ័សនូវកម្មវិធីកំណែទំរង់ខាងហិរញ្ញវត្ថុ ច្បាប់ និងស្ថាប័ន នឹងញុាំងឲ្យមានដំណើរការទៅមុខជាធម្មតានៃបដិដុល្លារូបនីយកម្មនៅកម្ពុជា គឺដូចគ្នានឹងដំណើរការដែលធ្លាប់មានរួចមកហើយនៅប្រទេសផ្សេងទៀត ។

## ៥. សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាធ្វើដំណើរទៅមុខបានច្រើនណាស់ហើយក្នុង ១០ឆ្នាំកន្លងមកនេះ ។ បន្ថែមលើជោគជ័យត្រចះត្រចង់ខាងសេដ្ឋកិច្ច កំណែទំរង់ខាងនយោបាយ ច្បាប់ និងស្ថាប័ន ក៏ទទួលបានជោគជ័យហួសពីការស្មានរបស់អ្នកវិភាគព័ត៌មានភាគច្រើនដែរ ។ យោងតាមជោគជ័យទាំងនេះ អ្នកវិភាគព័ត៌មានជាច្រើននាក់រំពឹងថា ដំណើរការបដិដុល្លារូបនីយកម្ម គួរតែជឿនលឿនទៅមុខហើយនៅពេលនេះ ប៉ុន្តែជាក់ស្តែងគេបែរជាពិនិត្យឃើញដុល្លារូបនីយកម្មបានកើនឡើងទៅវិញ ។ រឿងនេះបាននាំឲ្យមានការខកចិត្ត និងការអំពាវនាវកាន់តែច្រើនអោយលូកដៃធ្វើអន្តរាគមន៍ និងជាពិសេសឲ្យរដ្ឋាភិបាលព្យាយាមពង្រឹងអនុវត្តបដិដុល្លារូបនីយកម្ម ។

ក្នុងឯកសារនេះ យើងបានព្យាយាមពន្យល់ពីកំណើនដុល្លារូបនីយកម្មនាពេលថ្មីៗ ព្រមទាំងការយឺតយ៉ាវក្នុងការធ្វើបដិដុល្លារូបនីយកម្មនៅកម្ពុជា ។ យើងបានវែកញែកថា កំណើននាពេលថ្មីៗ គឺជាចំណែកមួយនៃដំណើរការអន្តរកាល ដែលបណ្តាលពី "ដំណឹងល្អ" ជាជាង "ដំណឹងអាក្រក់" ។ កំណើននេះទំនងជាបណ្តោះអាសន្ន និងគ្មានអ្វីគួរឲ្យភ័យផ្អើល ឡើយ ។ ចំណុចគួរបារម្ភជាងគេសំរាប់មនុស្សមួយចំនួន គឺភាពឋិតថេរនៃដុល្លារូបនីយកម្ម រឺលក្ខណៈមិនអាចផ្លាស់ប្តូរបាននៃដុល្លារូបនីយកម្ម ។ យើងយល់ថា ភាពឋិតថេរនេះបណ្តាលមកពីរបៀបវារៈកំណែទំរង់ដែលអនុវត្តមិនទាន់ចប់សព្វគ្រប់ និងភាពស្លឹកស្រពន់ក្នុងប្រព័ន្ធ ។ កាលៈទេសៈពិសេសនៅពេលដុល្លារហូរចូលមកក្នុងសេដ្ឋកិច្ចកម្ពុជា គួបផ្សំនឹងកំរិតដ៏ខ្ពស់នៃដុល្លារូបនីយកម្ម បានផ្តល់គំនិតថា បដិដុល្លារូបនីយកម្មទំនងត្រូវអូសបន្លាយយូរពេល ។ ដុល្លារូបនីយកម្មមិនមែនមិនអាចផ្លាស់ប្តូរបានដោយគ្មានអន្តរាគមន៍ដោយផ្ទាល់នោះទេ ប៉ុន្តែវាគ្រាន់តែត្រូវចំណាយពេល យូរថែមទៀត ។

ដោយសារហេតុផលដូចខាងលើ ការធ្វើសកម្មភាពខ្លាំងៗខាងគោលនយោបាយ ដូចជាការជំនះធ្វើបដិដុល្លារូបនីយកម្មជាដើម វាច្រើនតែត្រូវទទួលបរាជ័យ ហើយថែមទាំងអាចបង្កការខូចខាតទៀតផង ។ ដោយហេតុថា បន្ទុកចំណាយធ្វើបដិដុល្លារូបនីយកម្ម អាចធំជាងផលចំណេញទៅទៀត ដូច្នេះគេមានជំរើសមួយចំនួនទៀត ។ ជំរើសមួយ គឺការធ្វើដុល្លារូបនីយកម្មជាផ្លូវការ ប៉ុន្តែខាងមជ្ឈដ្ឋាននយោបាយគេទទួលយកវាមិនបានទេ ហើយផលចំណេញខាងសេដ្ឋកិច្ច ក៏មិនសូវច្បាស់ផង ។ ជំរើសមួយទៀត គឺការអនុមតិប្រើរបៀបរបបក្រុមប្រឹក្សារូបិយវត្ថុ ប៉ុន្តែវិធីនេះហាក់ដូចតក់ក្រហល់ពេក រឺក៏ធ្វើមិនកើតតែម្តងយោងតាមសមត្ថភាពហិរញ្ញវត្ថុសព្វថ្ងៃ ។

សរុបមក កម្ពុជាគួរអនុវត្តតាមគោលនយោបាយដែលមិនជ្រៀតជ្រែកដោយផ្ទាល់ទៅក្នុងរបៀបរបបខាងរូបិយវត្ថុ ប៉ុន្តែផ្តោតកំលាំងទៅលើការជំរុញកំណែទំរង់ដែលមានលក្ខណៈសំរបសំរួល ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំងកំណែទំរង់ខាងច្បាប់ និងខាងស្ថាប័ន ។ គេក៏បានរកឃើញហើយដែរនូវឧបសគ្គខាងស្ថាប័ននានាដែលត្រូវជំនះ ដើម្បីរៀបចំមូលដ្ឋាន សំរាប់ដំណើរការជឿនលឿនទៅមុខជាធម្មតានៃបដិដុល្លារូបនីយកម្ម ។

វាជាការលង់ខ្លៅទៅវិញទេបើសិនទស្សន៍ទាយថា ឱសថខាងគោលនយោបាយនេះអាចនាំទៅដល់ បដិដុល្លារូបនីយកម្មក្នុងទសវត្សរ៍ខាងមុខ ។ គេដឹងមិនច្បាស់ទេថា បដិដុល្លារូបនីយកម្មត្រូវចំណាយពេលយូរប៉ុណ្ណា ហើយវាអាចយូរជាង ការគិតឃើញទៅទៀត ។ ប៉ុន្តែវានឹងកើតមានឡើងតាមធម្មតា ដូចដែលធ្លាប់កើតមានរួចហើយនៅប្រទេសឥណ្ឌូនេស៊ី អ៊ីស្រាអែល ប៉ូឡូញ ម៉ិចស៊ិក អេហ្សិប ទួរគី (នៅមានច្រើនទៀត) ជាពិសេសប្រទេសជិតខាងកម្ពុជាតែម្តង គឺវៀតណាម ។ យោងតាមភស្តុតាងនៅអន្តរជាតិ និងការយល់ដឹងពីបរិបទកម្ពុជា គេមានរឿងមួយដែលច្បាស់លាស់គឺ ការព្យាយាមពង្រឹងអនុវត្តបដិដុល្លារូបនីយកម្ម នឹងធ្វើឲ្យវាអូសបន្លាយកាន់តែយូរថែមទៀត!

## ៤. តើត្រូវធ្វើអ្វី?

ដូចបានបង្ហាញក្នុងសេចក្តីផ្តើម សព្វថ្ងៃកាន់តែមានការអំពាវនាវច្រើន ហើយ ដើម្បីឲ្យពង្រឹងអនុវត្តបដិដុល្លារូបនីយកម្មនៅកម្ពុជា ។ មតិគាំទ្រការពង្រឹងអនុវត្តបដិដុល្លារូបនីយកម្ម អាចផុសចេញពីជំនឿថា ១) កម្ពុជាដល់ពេលត្រូវធ្វើបដិដុល្លារូបនីយកម្មហើយ និង ២) ដុល្លារូបនីយកម្មបង្កការខាតបង់ច្រើនជាងផលចំណេញ ។

ចំណុចទី២ អាចត្រឹមត្រូវច្រើន ។ លោក កង (២០០៥) បានប៉ាន់ស្មានថា កំហាតដោយការមិនបានបោះពុម្ពផ្សាយក្រដាសប្រាក់ (seigniorage) មានតំលៃ ៦៨២លានដុល្លារ គិតមកដល់ចុងឆ្នាំ២០០៤ និងត្រូវខាតបង់បន្ថែម ៦១លានដុល្លារក្នុងមួយឆ្នាំៗជាបន្តមកទៀត ។ នៅកម្ពុជា ទោះបីការប៉ាន់ស្មាននេះ ស៊ីគ្នានឹងភស្តុតាងនៅអន្តរជាតិ ដែលបង្ហាញពីកំហាតប្រចាំឆ្នាំប្រហែល ២% នៃ ផសស ក្តី ប៉ុន្តែវាអាចទាបជាងការពិតសំរាប់ប្រទេសកម្ពុជា ពីព្រោះនៅកម្ពុជាមានលំហូរចូលរូបិយវត្ថុបរទេសយ៉ាងច្រើនដែលមិនមានកត់ត្រា/មិនអាចកំណត់បាន ។ លើសពីនេះ កម្ពុជាសឹងតែបាត់បង់ស្វ័យភាពទាំងស្រុងក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។ កំហិតនេះអាចមើលឃើញច្បាស់នាបច្ចុប្បន្នតែម្តង នៅពេលដែលធនាគារកណ្តាលសហរដ្ឋអាមេរិកកំពុងអនុវត្តគោលនយោបាយពង្រីកបរិមាណរូបិយវត្ថុ ខណៈដែលកម្ពុជាត្រូវរឹតបន្តឹងវាដើម្បីកាត់បន្ថយកំណើនសម្ពាធអតិផរណា។ ទោះបីយើងមិនគិតពីកំហិតខាងគោលនយោបាយ និងលំហូរដុល្លារដែលមិនបានកត់ត្រាក្តី ក៏ត្រឹមតែតួលេខប៉ាន់ស្មានកំហាតដោយមិនបានបោះពុម្ពផ្សាយក្រដាសប្រាក់នេះមួយមុខ វាធំជាស្រេច ជាងផលចំណេញដែលបានពីស្ថិរភាពថ្លៃល្អ អត្រាប្តូរប្រាក់មិនសូវឡើងចុះ និងកត្តាបង្កទំនុកចិត្តលើគោលនយោបាយម៉ាក្រូផ្សេងៗទៀត ។ ប៉ុន្តែផលចំណេញទាំងនេះ កាន់តែពិបាកកំណត់បរិមាណជាងកំហាតទៅទៀត ។ ទោះបីជាកំហាតមានច្រើនជាងផលចំណេញពិតមែនក្តី តើរឿងនេះមានន័យថា កម្ពុជាដល់ពេលត្រូវធ្វើបដិដុល្លារូបនីយកម្មមែនរឺយ៉ាងណា ។ សរុបមក វាដូចគ្នានឹងសំណួរថា ការពង្រឹងអនុវត្តដុល្លារូបនីយកម្ម នឹងជួយកែលំអស្ថានភាពបច្ចុប្បន្នរឺយ៉ាងណា ។ ប៉ុន្តែភស្តុតាងនៅអន្តរជាតិ បានបង្ហាញខុសពីនេះ (សូមអានឯកសារ Menon 2008) ។

តាមពិត យើងមិនចាំបាច់មើលទៅឆ្ងាយរហូតដល់ប្រទេសគុយបា លីបេរីយ៉ា រីរុស្ស៊ី ដើម្បីបង្ហាញពីការលំបាកពាក់ព័ន្ធនឹងការព្យាយាមពង្រឹងអនុវត្តបដិដុល្លារូបនីយកម្មនោះទេ ។ យើងមើលត្រឹមតែប្រទេសឡាវគ្រប់គ្រាន់ហើយ ។ នៅពេលធនាគារជាតិឡាវចាត់វិធានការពង្រឹងអនុវត្តន៍ក្រឹត្យលេខ ២២ ចុះខែមិថុនា ២០០៧ (ដែលចែងថា មានតែប្រាក់គីបឡាវប៉ុណ្ណោះ ដែលអាចប្រើជាមធ្យោបាយទូទាត់សំរាប់គ្រប់ប្រតិបត្តិការក្នុងស្រុក) លទ្ធផលទទួលបាន គឺការខាតបង់ ។ ការធ្លាក់ថ្លៃប្រាក់គីបឡាវក្រោយពេលចាត់វិធានការ បានកាត់បន្ថយតំលៃនៃចំណែកប្រាក់គីបនៅក្នុងស្តុករូបិយវត្ថុ (សូមអានឯកសារ Menon 2007) ។ ដូច្នេះការស្រាយបង្ហាញថា ដុល្លារូបនីយកម្មបង្កកំហាតច្រើនជាងផលចំណេញ គឺមិនគ្រប់គ្រាន់ទេ ។ អ្នកគាំទ្រការពង្រឹងអនុវត្តបដិដុល្លារូបនីយកម្ម ត្រូវតែបង្ហាញផងដែរថា ដំណោះស្រាយរបស់ពួកគេ នឹងធ្វើឲ្យស្ថានភាពបច្ចុប្បន្នប្រែប្រួលប្រសើរឡើង ។ ភស្តុតាងនៅអន្តរជាតិទាំងអស់ បានបង្ហាញថា រឿងបែបនេះកំរមានណាស់ ។

ប្រសិនបើការពង្រឹងអនុវត្ត មិនមែនជាដំណោះស្រាយ ហើយកំហាតវាធំជាងផលចំណេញ ដូច្នេះតើគួរធ្វើអ្វី? ជំរើសគោលនយោបាយមានច្រើនណាស់ ដោយនៅចុងម្ខាង គឺការពង្រឹងអនុវត្តបដិដុល្លារូបនីយកម្ម និងចុងម្ខាងទៀត គឺមានការធ្វើដុល្លារូបនីយកម្មជាផ្លូវការ ហើយនៅចន្លោះកណ្តាល គឺការរៀបចំក្រុមប្រឹក្សារូបិយវត្ថុ (currency board arrangements: CBAs) និងវិធីសាស្ត្រលូកដៃធ្វើអន្តរាគមន៍ ។[៤]

យើងគួរចាប់ផ្តើមពិនិត្យ ពីការធ្វើដុល្លារូបនីយកម្មជាផ្លូវការ ។ ប្រទេសមួយចំនួននៅអាមេរិកឡាទីន ដូចជា អេក្វាទ័រ ឯលសាល់វ៉ាឌ័រ និងប៉ាណាម៉ា បានអនុម័តជាផ្លូវការយកដុល្លារអាមេរិក ធ្វើជារូបិយប័ណ្ណរបស់ខ្លួន ។ តាំងពីនោះមក ប្រទេសទាំងនេះភាគច្រើនមានអត្រាអតិផរណានៅថេរល្អ ជាពិសេសប៉ាណាម៉ា ដែលគេលើកសរសើរជារឿយៗថា ជារឿងជោគជ័យនៃដុល្លារូបនីយកម្មជាផ្លូវការ ។ យោងតាមដុល្លារូបនីយកម្មកំរិតខ្ពស់នៅកម្ពុជា តើជំរើសនេះអនុវត្តបានរឺទេ? ជំរើសនេះទំនងអនុវត្តមិនបានទេ ដោយសារហេតុផលមួយចំនួន ។ ខុសប្លែកពីបណ្តាប្រទេសនៅអាមេរិកឡាទីន ដែលជ្រើសយកដុល្លារូបនីយកម្មជាផ្លូវការ សេដ្ឋកិច្ចកម្ពុជាមិនបានធ្វើសមាហរណកម្មជិតស្និទ្ធជាមួយសេដ្ឋកិច្ចអាមេរិកទេ ហើយកន្លងមកសហរដ្ឋអាមេរិក ក៏មិនសូវចង់បង្វិលប្រាក់ចំណូលលើការបោះពុម្ពផ្សាយក្រដាសប្រាក់ មកឲ្យប្រទេសដែលធ្វើដុល្លារូបនីយកម្មជាផ្លូវការដែរ ។ ដូចនេះប្រាក់ចំណូលលើការបោះពុម្ពផ្សាយក្រដាសប្រាក់ដែលកម្ពុជាទទួលបានសព្វថ្ងៃ នឹងអាចបាត់បង់អស់ដោយសារដុល្លារូបនីយកម្មជាផ្លូវការ ។ ប៉ុន្តែឧសគ្គចំបងដែលរារាំងដុល្លារូបនីយកម្មជាផ្លូវការ គឺបញ្ហានយោបាយ ។ រដ្ឋាភិបាលទំនងមិនចំណាយពេលច្រើនពិចារណាពីជំរើសនេះទេ ពីព្រោះមានការតាំងចិត្តខាងនយោបាយថា ត្រូវធ្វើបដិដុល្លារូបនីយកម្ម ។

ធូរបន្តិចជាងជំរើសខាងលើនេះ គឺការរៀបចំក្រុមប្រឹក្សារូបិយវត្ថុ (CBA) ដែលជិតដូចដុល្លារូបនីយកម្មជាផ្លូវការដែរ ប៉ុន្តែមានចំណុចខុសគ្នាសំខាន់ៗមួយចំនួន ។ ទី១ CBA មិនសូវរឹងកំព្រឹសទេ ពីព្រោះគេអាចបញ្ចុះតំលៃរូបិយវត្ថុ (devaluation) បាន ។ ទី២ CBA វាបង្កើត

[៤] ជំរើសមួយទៀត គឺការប្រើរូបិយវត្ថុតែមួយ រឺសហភាពរូបិយវត្ថុ ។ ជំរើសនេះមានរៀបរាប់លំអិតក្នុងឯកសារ Menon (2008) ។ យោងតាមការវិភាគនោះ ជំរើសនេះហាក់ដូចអនុវត្តមិនកើតទេនៅកម្ពុជា រឺប្រទេសជិតខាងកម្ពុជាក្នុងពេលសព្វថ្ងៃ ពីព្រោះការរៀបចំដែលអាចធ្វើទៅបាន វាមិនអាចបំពេញលក្ខខណ្ឌនៃតំបន់រូបិយវត្ថុដ៏ប្រសើរនោះទេ ។

ឡើងវិញនូវប្រាក់ចំណូលលើការបោះពុម្ពផ្សាយក្រដាសប្រាក់ រីឯដុល្លារូបនីយកម្មជាផ្លូវការ វាបំបាត់ចំណូលនេះចោលទាំងស្រុង ។ ហុងកុងជាករណីមួយដែលគេដឹងច្បាស់ថា បានអនុវត្តប្រើ CBA ប៉ុន្តែក៏មានសេដ្ឋកិច្ចអន្តរកាលមួយចំនួនដូចជានៅ Lithuania, Estonia និង Bosnia ដែលបានអនុវត្តប្រព័ន្ធប្រហាក់ប្រហែល CBA បានជោគជ័យល្អដោយចងភ្ជាប់រូបិយវត្ថុក្នុងស្រុករបស់ខ្លួនទៅនឹងប្រាក់អឺរ៉ូ ។[៥]

តើនៅកម្ពុជា CBA អាចអនុវត្តបានបែបណា? នៅពេលនេះ ធនបំរុងផ្លូវការមានចំនួនប្រហែល ៣ដងនៃប្រាក់រៀលកំពុងចរាចរ បើគិតតាមអត្រាប្តូរប្រាក់បច្ចុប្បន្ន ។ តួលេខនេះឃើញច្រើនសំបើមណាស់ ប៉ុន្តែជាក់ស្តែង ចំណែករូបិយវត្ថុបរទេសកំពុងចរាចរមានប្រហែលពី ៨៥ ទៅ ៩៥% នៃរូបិយវត្ថុកំពុងចរាចរសរុប (de Zamarocksy and Sa 2002) ។ ដូច្នេះគិតជាមធ្យម ប្រាក់រៀលមានប្រហែលតែ ១០% នៃរូបិយវត្ថុកំពុងចរាចរប៉ុណ្ណោះ ។ ដើម្បីជំនួសឲ្យរូបិយវត្ថុបរទេសកំពុងចរាចរនៅពេលនេះ គេត្រូវបង្កើនធនបំរុងផ្លូវការនេះមួយជាបី ។ ប្រសិនបើមិនបង្កើនកំចីរដ្ឋាភិបាលយ៉ាងច្រើនៗទេ (កំចីភាគច្រើនត្រូវស្វែងរកពីក្រៅប្រទេស) រឿងនេះប្រហែលធ្វើមិនកើតឡើយ ។[៦]

ដូចនេះ ទោះបី CBAs អាចជាជំរើសមួយល្អដែរ ទោះបណ្តោះអាសន្ន រឺជាប់លាប់ក្តី ប៉ុន្តែកម្ពុជាពុំមានសមត្ថភាពហិរញ្ញវត្ថុអនុវត្តវាទេក្នុងពេលបច្ចុប្បន្ននេះ ។

ជំរើសជាបន្តមកទៀតគឺ "លូកដៃធ្វើអន្តរាគមន៍ដោយពន្លឿនកំណែទំរង់"។ក្នុងជំរើសនេះ មានការធ្វើអន្តរាគមន៍ដោយផ្ទាល់តិចបំផុត ប៉ុន្តែមានការផ្លាស់ប្តូរជាប្រយោលច្រើនបំផុតនៅក្នុងគោលនយោបាយ និងវិធានការកំណែទំរង់ផ្សេងៗ ។ ក្នុងវិធីសាស្ត្រនេះ របៀបរៀបចំបច្ចុប្បន្នខាងរូបិយវត្ថុគេទុកវាតទៅទៀត ប៉ុន្តែគេផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទំរង់គោលនយោបាយដើម្បីជួយសំរួល ។ ស្ថានភាពម៉ាក្រូត្រូវបន្តកែលំអឡើងដូចក្នុងទសវត្សរ៍កន្លងមកនេះ ហើយស្ថានភាពនយោបាយត្រូវមានស្ថិរភាពជានិច្ច ។ ទាំងនេះ គឺជាលក្ខខណ្ឌចាំបាច់បំផុត ដើម្បីអាចញ៉ាំងឲ្យដុល្លារូបនីយកម្មវិលបញ្ច្រាសមកវិញបានយូរអង្វែង ។

នៅមានការងារត្រូវធ្វើជាច្រើនទៀត ។ឧទាហរណ៍ បញ្ហាប្រឈមក្នុងរយៈពេលមធ្យមសំខាន់ៗ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដូចជា ការបង្កើនអន្តរការីកម្ម ការពង្រឹងចំណងទាក់ទងរវាងធនាគារនិងមីក្រូហិរញ្ញវត្ថុ និងកំណែលំអប្រតិបត្តិការស្ថាប័នហិរញ្ញវត្ថុជារួម ត្រូវតែដោះស្រាយឲ្យបាន ។ ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុក៏សំខាន់បំផុតដែរ ដើម្បីស្តារទំនុកចិត្តលើប្រាក់រៀលឡើងវិញ ។ តួនាទីលេចធ្លោមួយដែលកំណែទំរង់ម៉ាក្រូសេដ្ឋកិច្ចអាចបំពេញបានក្នុងការធ្វើបដិដុល្លារូបនីយកម្ម គឺកំណែទំរង់ពន្ធដារ ។ តំរូវការប្រាក់រៀលមួយភាគធំ ជាប់ទាក់ទងនឹងការបង់ពន្ធ ពីព្រោះពន្ធត្រូវបង់ជារៀល ។ មូលដ្ឋានរកចំណូលតាមរយៈការប្រមូលពន្ធ ទំនងជានឹងកើនឡើង ជាពិសេសក្នុងបរិបទមានកំណើនសេដ្ឋកិច្ចយូរអង្វែង ដែលជាលទ្ធផលនៃ ១) កំណែទំរង់សារពើពន្ធក្នុងនេះមានទាំងការពង្រីកមូលដ្ឋានយកពន្ធផង ២) កំណែលំអយន្តការប្រមូលពន្ធ និង ៣) គោលនយោបាយដែលរចនារៀបចំឡើងដើម្បីទប់ស្កាត់ការជៀសវាងពន្ធ ។ ការងារនេះ នឹងជួយបង្កើនតំរូវការប្រាក់រៀលដោយផ្ទាល់ ក៏ដូចជាចីរភាពខាងហិរញ្ញវត្ថុ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ហើយទាំងអស់នេះ នឹងជួយរួមចំណែកដល់បដិដុល្លារូបនីយកម្ម ។

បញ្ហាម៉ាក្រូសេដ្ឋកិច្ច នយោបាយ និងហិរញ្ញវត្ថុទាំងឡាយដូចខាងលើ គឺជាមុខចំណាយធំៗមួយចំនួនដែលត្រូវធ្វើ ។ នៅមានឧបសគ្គខាងស្ថាប័នជាច្រើនទៀតដែលត្រូវបំបាត់ចោល ហើយដែលបច្ចុប្បន្ននេះកំពុងបង្កើនភាពខុសគ្នា ទាំងក្នុងការពិតជាក់ស្តែង និងក្នុងចំណាប់អារម្មណ៍ រវាងប្រាក់ដុល្លារ និងប្រាក់រៀល ។ឧបសគ្គទាំងនេះបានរារាំងដំណើរការទៅមុខជាបណ្តើរៗនៃបដិដុល្លារូបនីយកម្ម ហើយឧបសគ្គខ្លះ បានរារាំងជាច្រើនទសវត្សរ៍មកហើយ ដូចជា ចំណូលចិត្តក្នុងការផ្តល់បៀវត្សរ៍ជាប្រាក់ដុល្លារអាមេរិក ទៅឲ្យពលករក្នុងវិស័យឯកជន ។ ច្បាប់ការងារ ដែលបានកំណត់បៀវត្សរ៍អប្បបរមាជាប្រាក់ដុល្លារអាមេរិក គឺជាឧទាហរណ៍ច្បាស់ក្រឡែតមួយ ។ ឧទាហរណ៍មួយទៀត គឺការពិតជាក់ស្តែងដែលបណ្តាអង្គការជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) តែងបង់បៀវត្សរ៍ឲ្យបុគ្គលិកខ្លួនជាដុល្លារអាមេរិកសុទ្ធ ប៉ុន្តែនៅតាមប្រទេសផ្សេងទៀត អង្គការនានាដូចជាខាងអង្គការសហប្រជាជាតិជាដើម ច្រើនតែបង់យ៉ាងតិច ៣០% ជារូបិយវត្ថុនៃប្រទេសម្ចាស់ផ្ទះ ។ ជំហានដ៏មានប្រយោជន៍មួយដើម្បីបង្កើតលក្ខខណ្ឌល្អជាមុនសំរាប់បដិដុល្លារូបនីយកម្ម គឺការបំបាត់ចោលស្ថានភាពអំណោយផលដល់ប្រាក់ដុល្លារ ក្នុងការបង់ប្រាក់បៀវត្សរ៍នេះ ។ ចំពោះបៀវត្សរ៍របស់មន្ត្រីរាជការ គឺច្បាស់ជាត្រូវបង់ជាប្រាក់រៀលហើយ ប៉ុន្តែចំនួនទឹកប្រាក់ប៉ុណ្ណា។ គេអាចចងភ្ជាប់វាបានទៅនឹងដុល្លារអាមេរិក ដើម្បីធានាអំណាចទិញរបស់សាមីជន ។

យោងតាមការវែកញែកដូចខាងលើ នៅពេលមានតំរូវការប្រាក់រៀល កំហិតផ្សេងៗខាងស្ថាប័នដែលរារាំងដល់ការប្រើប្រាក់រៀលកាន់តែច្រើន គឺគួរតែបំបាត់ចោល ។ ឧទាហរណ៍មួយទៀតជាប់ទាក់ទងនឹង

---

៥ ប្រទេសអាហ្សង់ទីន មានប្រព័ន្ធ CBA ចងភ្ជាប់ជាមួយដុល្លារអាមេរិក រហូតដល់ឆ្នាំ២០០២ ហើយប្រទេសជាច្រើននៅតំបន់ការាអ៊ីប បន្តប្រើ CBA ចងភ្ជាប់ជាមួយដុល្លារ ។

៦ ក្នុងនេះគេសន្មតថា រូបិយវត្ថុបរទេសកំពុងចរាចរ គឺទុកសំរាប់ធ្វើប្រតិបត្តិការដោះដូរ ឬធ្វើជាមធ្យោបាយទូទាត់។ប៉ុន្តែមួយចំណែកនៃរូបិយវត្ថុបរទេសកំពុងចរាចរ គឺទុកសំរាប់បំរើមុខងារស្តុកទុកធនធាន ពីព្រោះគេមានទំនុកចិត្តទាបទៅលើប្រព័ន្ធធនាគារក្នុងស្រុក ។ ចំណែកនេះមិនចាំបាច់ជំនួសវិញទេក្នុងការអនុវត្ត CBA ។ ចំណែកនេះគេមិនដឹងចំនួនវាច្បាស់លាស់ទេ ប៉ុន្តែវាក៏មិនច្រើនដល់ថ្នាក់ធ្វើឲ្យប្រែប្រួលដល់ការសន្និដ្ឋានថា ការអនុវត្ត CBA ជាបន្ទុកហិរញ្ញវត្ថុមួយធ្ងន់ធ្ងរលើរដ្ឋាភិបាល ។